

# ឈានទៅចាប់យកអ្វី ?

**សេរីការ**

អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ ជ្រើសរើស ការដោះស្រាយ ស្រំដែល ដែលខ្លួនធ្លាប់ប្រើគ្មានប្រសិទ្ធិភាពអ្វីនោះឡើយ។ សួរថា តើ ពួកគាត់ ទុកប្រជាពលរដ្ឋ ជាអ្នកល្ងង់ខ្លៅ អាចបញ្ឆោតបានរាល់ដង ឬ ពួក គាត់ជាពួកលលា គ្មានចេះដកការពិសោធពីទង្វើគ្មានលទ្ធផល យក មកធ្វើជាមេរៀន។ អធិយោគ[1] ក្នុងការភាន់ច្រឡំ មិនមែនជា សញ្ញា នៃ បញ្ហានោះឡើយ ផ្ទុយទៅវិញ វាជា ភាពកន្ទ្រោន នៅក្នុងភពអវិជ្ជា ដូចយ៉ាង៖

## ការដោះស្រាយតាមផ្លូវព្រះមហាក្សត្រ

អនុស្សតិ[2] វានៅមាន ថ្មីៗ នៅឡើយ លើ អាក្សកិរិយា ព្រះមហាក្សត្រ ក្រុងកម្ពុជា ក្នុងវិបត្តិនយោបាយខ្មែរ គឺ ព្រះអង្គតែងតែស្ថិតនៅខាង ពួកអ្នកប្រព្រឹត្តអំពើអយុត្តិធម៌ជានិច្ច ព្រោះ ព្រះអង្គ ជា មហាក្សត្រ ដែលក្រុមនោះ គេជ្រើសតាំងឡើង ដើម្បី បំរើ ប្រយោជន៍នយោបាយ របស់ពួកគេ ដូច្នេះ ព្រះអង្គ គង់លើបល្ល័ងបាន ត្រូវមានសរុណ: (សេច ក្តីទីពឹង) លើពួកគេ ពុំនោះ ព្រះអង្គ នឹងអាចមានបញ្ហាដល់រាជ្យរបស់ ព្រះអង្គ។ រឿងនេះ នរណា ក៏គេដឹងដែរថា ស្តេចខ្មែរបច្ចុប្បន្ន ជា ឧបករណ៍នយោបាយ របស់យួនកុម្មុយនិស្ត តែបើពួកអ្នកដឹកនាំគណ បក្សប្រឆាំង ធ្វើជាមិនដឹង គឺពួកគាត់ជាអ្នកសក់ឡក់[3] យកព្រះមហា ក្សត្រ មកលែងសើច នាំគ្នាថ្វាយ ប្រជាបដ្ឋនាលិខិត[4] ដល់ ព្រះអង្គ

---

[1] អធិយោគ ; persévérance។
[2] អនុស្សតិ ; souvenir។
[3] សក់ឡក់ ; blagueur។
[4] ប្រជាបដ្ឋនាលិខិត ; pétition populaire។

នោះបីដឹងថា ព្រះអង្គ គ្មានអំណាចប្រត្យក្ស[5] និង សិទ្ធិសីលធម៌ អ្វី សំរាប់ធ្វើអន្តរាគមន៍ ក្នុងវិបត្តិនយោបាយបច្ចុប្បន្ន ក៏ដូចសព្វដងដែលវាធ្លាប់មានកើតឡើងរួចមកហើយ។ តែ ព្រះមហាក្សត្រ ក៏ឆ្លើយតមវិញតាមការមាក់ងាយដល់ប្រជាពលរដ្ឋ ដូចយ៉ាងអោយមន្ត្រីរាជវាំង ចេញមកទទួលញត្តិប្រជារាស្ត្រ នៅក្រៅរបងរាជវាំង ហាក់បីដូចទុក ពួកអ្នកតំណាងរាស្ត្រ ដែលនាំញត្តិទៅថ្វាយព្រះអង្គ ជាមនុស្សគ្មានតម្លៃអ្វីបន្តិចនោះឡើយ។ អាកប្បកិរិយាបែបនេះ ជាកញ្ឆ[6] ដែលនាំអោយព្រះអង្គ មិនអាចជា រតនៈក្សត្រ[7] នោះឡើយចំពោះប្រជារាស្ត្រ។ ទោះជាមានប្រតិកម្មអវិជ្ជមាន បែបនេះក៏ដោយ ក៏ពួកអ្នកដឹកនាំគណបក្សសង្គ្រោះជាតិនៅតែទទូច ប្រមូលហត្ថលេខានៃប្រជាពលរដ្ឋ យកទៅថ្វាយព្រះមហាក្សត្រ បន្តទៀត។ ករណីបែបនេះ លោក កឹម សុខា ខ្លួនឯង ក៏គាត់ធ្លាប់និយាយ ពីអតិតកាលថា ការរក សេចក្តីរំពឹងពី ព្រះមហាក្សត្រ ជាការសង្ឃឹមខកចិត្តតែប៉ុណ្ណោះ។

## វិធីដើងល័ព្ធ[8]

ប្រាកដណាស់ថា ការតស៊ូ ត្រូវធ្វើសកម្មភាពជានិច្ច តែបើ សកម្មភាពនោះ វាជា វញ្ឈកម្ម[9] គឺវានឹងនាំអោយ ប្រជាពលរដ្ឋ ខូចទឹកចិត្ត នៅពេលណាមួយជាពុំខាន ព្រោះ ធនធានមនុស្ស វាមានកំរិត ទាំងផ្លូវរូបវន្ត និង គោលចំណង់ របស់វា។ ការប្រមូលអ្នកគាំទ្រអោយបានចំនួនច្រើនសំរាប់ ទ្រទ្រង់ការតស៊ូអោយមានរូបភាពពិតប្រាកដ គឺ ដើម្បីធ្វើមហាបាតុកម្មអហិង្សា ព្រោះ វាជា ជិពវិញ្ញាត្តិ[10] នៃ កម្លាំងមតិប្រឆាំងនឹង អំពើអយុត្តិធម៌ ដែលអាជ្ញាធរយួន តែងតែប្រព្រឹត្តជាអនន្តរ មក

5 អំណាចប្រត្យក្ស ; pouvoir réel។
6 កញ្ឆ ; ការគ្មានសុជីវធម៌ ; impoli។
7 រតនៈជន ; ជនដ៏ប្រសើរ ជាទីរីករាយ ជាទីសង្ឃឹមកក់ក្តៅ។
8 វិធីដើងល័ព្ធ ; របៀបចាត់ការ ; mode opératoire។
9 វញ្ឈកម្ម, ការងារឥតផល, អំពើឥតប្រយោជន៍។
10 ជិពវិញ្ញាត្តិ ; សំដែងទឹកចិត្តពិត ; expression vivante។

លើអ្នកស្នេហាជាតិ និង ប្រជាពលរដ្ឋខ្មែរ, ជាពិសេស យកច្បាប់រដ្ឋធម្មនុញ្ញខ្មែរមកជញ្ជាន់ បីដូចយក សិរសាប្រជាជាតិខ្មែរ មកជាន់ ដើម្បីប្រមាទមាក់ងាយ។ ដូច្នេះនាំគ្នាអង្គុយចាំយួនចាប់ខ្លួនលោកកឹមសុខាសិន ទើបនាំគ្នាធ្វើបាតុកម្ម វាជា វិធីការពារខ្លួន គ្មានប្រសិទ្ធិភាពចំពោះការវាយលុក របស់អ្នកដឹកនាំយួននៅស្រុកខ្មែរ៖ គេការពារខ្លួនមុនពេលចាប់ មិនមែន ចាប់រួចហើយ ទើបនាំគ្នា ការពារខ្លួននោះឡើយ ព្រោះថា កម្ម និង ប្រតិកម្ម វាមាន អនុភាព ខុសគ្នា៖ កម្ម គឺជាសកម្មភាព រកដំណោះស្រាយ ដែលចង់បានជាស្ថាពរ ក្នុងគោលដៅវិសាយ, រីឯ ប្រតិកម្មវិញ គឺជា សកម្មភាព រងនឹងកម្លាំងវាយលុក លើគោលដៅដែលមានដែនកំណត់ចង្អៀត។ ហេតុនេះឯងពួកអ្នកដឹកនាំគណបក្សប្រឆាំង ត្រូវដឹងខ្លួនឯងអោយច្បាស់អំពីការចង់បានរបស់ខ្លួនក្នុងករណី លោក កឹម សុខា៖ គឺថា ចង់បាន ត្រឹមតែកុំអោយអាថ្ងាធរយួនកុំចាប់ខ្លួនលោក កឹម សុខា ឬ លើកនេះ ចង់ការពារ នូវ យុត្តិធម៌ទូទៅ ដែលអាថ្ងាធរយួន តែងតែបំពានមកលើច្បាប់ខ្មែររហូតមកដល់សព្វថ្ងៃនេះ។ បច្ចុប្បន្ននេះ ពួកអ្នកដឹកនាំគណបក្សសង្គ្រោះជាតិគាត់កំពុងធ្វើដូចគ្នានឹងទង្វើឆ្នាំ ២០១៤ នៅទីលានប្រជាធិបតេយ្យ, ដូច្នេះរបៀបចាស់ វានឹងនាំមកនូវលទ្ធផលចាស់នោះដែរ។ នរណាក៏គេដឹងដែរថា ពេលវេលាវាធ្វើការអោយ អាថ្ងាធរយួន ព្រោះយួន គេស្គាល់មារយាទ របស់ពួកអ្នកដឹងនាំគណបក្សប្រឆាំង ច្បាស់ណាស់ គឺ៖ ផ្អិនក្បាល ស៊ីក្បាល ផ្អិនកន្ទុយ ស៊ីកន្ទុយ។

## ទីបញ្ចប់ វានឹងមានប្រយោជន៍អ្វី ?

ឈានទៅចាប់យកអ្វី ? ទទេ ? ត្បិត សំណួរ របស់យើង វាគ្មានចម្លើយជាទូទៅ, ដូច្នេះ សុំទុកការ:ជូន មិត្តអ្នកអាន ឆ្លើយដោយខ្លួនឯងព្រោះរឿងនេះជារឿងរបស់ប្រជាជាតិ។ ជាពិសេស វិស័យមតិ របស់យើងមិនមែនមាន លក្ខណ:ជា ការវិនិច្ឆ័យ ដាក់កំហុស ដល់ពួកអ្នកដឹកនាំ

គណបក្សប្រឆាំងនោះឡើយ តែគ្រាន់តែជា វិធីសាស្ត្រ ដែលយើងយល់ឃើញតែប៉ុណ្ណោះ។ ព្រោះកំហុស របស់ ពួកអ្នកដឹងនាំគណបក្សសង្គ្រោះជាតិ វាមានរួចស្រេចនៅក្នុងទង្វើខុសផ្គួនរបស់ពួកគាត់តាំងពីដើមអាណត្តិរដ្ឋសភាបច្ចុប្បន្ន គឺថា ពួកគាត់ នាំគ្នាជួយប្តូររូប រដ្ឋសភាខុសច្បាប់ អោយក្លាយជា សភាជាតិ ហើយនាំគ្នា ចូលធ្វើ សហការដោយស្ម័គ្រចិត្ត។ ដោយអកុសល រដ្ឋសភានេះឯង ដែលបានបោះឆ្នោត ខុសច្បាប់រដ្ឋធម្មនុញ្ញ ដកអភ័យឯកសិទ្ធិ លោកសម រង្ស៊ី និង អ៊ុំ សំអាន, តើពេលនោះពួកគាត់មានប្រតិកម្មអ្វីដែរ ? ពួកគាត់នៅតែបន្ត ធ្វើសហការជាប្រក្រតីនៅក្នុងរដ្ឋសភា, សួរថាតើ ករណី លោក កឹម សុខា វាខុសគ្នាអ្វីនឹង ករណី លោក សម រង្ស៊ី និង អ៊ុំ សំអាន ? បើសិនជាពួកគាត់មានចម្លើយសមហេតុផលនឹងសំណួរនេះ គឺច្បាស់ជាពួកគាត់មិននៅចាំមើលអាផ្លាធរយួន នឹងចាប់ខ្លួន លោក កឹម សុខា នោះឡើយ ព្រោះ អង្គុយចាំនេះគឺជា យុទ្ធកថា[11] បានតែចចា[12]រឿងលន្លង់លន្លោចជាអ្នករងគ្រោះ ខុសពីការប្រកាសថា ជា អ្នកសង្គ្រោះ ឬ ទំពាអៀងនៃបរាជ័យ នៅក្នុងឆ្នាំ២០១៤ ដែលមានរាស្ត្រជាសាខាគ្រោះ[13] តែប៉ុណ្ណោះ៕

បណ្តាំ របស់ ភិក្ខុ ប៉ាង ខាត់ :

បុគ្គលពុំគម្បីចងមិត្តសម្លាញ់ ឬ ចងស្ពានមេត្រីជាមួយទុរជនឲសោះ ពីព្រោះមនុស្សនោះប្រៀបដូចធ្យូង បើនៅក្តៅ វារលាកដៃ បើរលត់ វាប្រឡាក់ដៃ។

---

[11] យុទ្ធកថា ; épopée ; ថ្លែងរឿងលន្លង់លន្លោចជាពាក្យកំណាព្យ។
[12] ចចា ; parler។
[13] សាខាគ្រោះ ; victime collatérale។